# តើមានអ្វីកើតឡើងបន្ទាប់ពីខ្ញុំត្រូវបានទទួលឱ្យចូលព្យាបាលនៅ My Home Hospital (មន្ទីរពេទ្យមានមូលដ្ឋានតាមផ្ទះរបស់ខ្ញុំ)?

## ការទទួលឱ្យចូលព្យាបាល

អ្នកនឹងត្រូវបានទទួលឱ្យចូលព្យាបាលនៅ My Home Hospital ក្រោមការថែទាំរបស់វេជ្ជបណ្ឌិតរបស់ My Home Hospital ដែលនឹងមើលការខុសត្រូវលើការថែទាំរបស់អ្នក។

## ផែនការថែទាំ

អ្នកសម្របសម្រួលក្នុងការថែទាំរបស់ My Home Hospital គឺជាគិលានុប្បដ្ឋាកដែលមានបទពិសោធន៍ទាំងអស់ ហើយនឹងបង្កើតផែនការថែទាំរបស់អ្នក ក្នុងភាពជាដៃគូជាមួយអ្នក អ្នកថែទាំ និងក្រុមថែទាំសុខភាពរបស់អ្នក។

## ការមកពិនិត្យតាមផ្ទះជាលើកដំបូង

គិលានុប្បដ្ឋាកនឹងមកពិនិត្យតាមផ្ទះរបស់អ្នក ដើម្បីផ្តល់ការថែទាំជាលើកដំបូងរបស់អ្នក។ ពួកគេក៏នឹងរៀបចំបច្ចេកវិទ្យាពិនិត្យសុខភាពនៅផ្ទះរបស់អ្នក ហើយបង្ហាញអ្នក (និងមនុស្សជាទីស្រឡាញ់ ឬអ្នកថែទាំរបស់អ្នក) អំពីរបៀបប្រើប្រាស់បច្ចេកវិទ្យានេះ។ នេះរួមបញ្ចូលទាំងថេប្លេតដំណើរការដោយប៉ះអេក្រង់ និងឧបករណ៍នានាសម្រាប់វាស់ និងកត់ត្រាការពិនិត្យសុខភាព ដូចជាសីតុណ្ហភាព សម្ពាធឈាម និងជីពចររបស់អ្នក។

## ការព្យាបាល

គិលានុប្បដ្ឋាក ឬអ្នកជំនាញថែទាំសុខភាពផ្សេងទៀតរបស់ My Home Hospital អាចរួមមានវេជ្ជបណ្ឌិតនានាដែលនឹងអញ្ជើញមកពិនិត្យអ្នកប្រចាំថ្ងៃនៅផ្ទះរបស់អ្នក ដើម្បីផ្តល់ការថែទាំដែលអ្នកត្រូវការ។ រាល់ការអញ្ជើញមកពិនិត្យទាំងអស់នឹងត្រូវបានសម្របសម្រួលដោយ អ្នកសម្របសម្រួលក្នុងការថែទាំរបស់ My Home Hospital។

## ការអនុញ្ញាតឱ្យចាកចេញពីការព្យាបាល

នៅពេលដែលស្ថានភាពរបស់អ្នកបានល្អប្រសើរឡើង វេជ្ជបណ្ឌិតរបស់អ្នកនឹងចាប់ផ្តើមនិយាយជាមួយអ្នកអំពីការអនុញ្ញាតឱ្យចាកចេញពីការព្យាបាលរបស់ My Home Hospital។

## ជំហានបន្ទាប់

អ្នកសម្របសម្រួលក្នុងការថែទាំរបស់ My Home Hospital នឹងធ្វើការជាមួយវេជ្ជបណ្ឌិតព្យាបាលរោគទូទៅ (GP) របស់អ្នក និងអ្នកផ្តល់សេវាកម្មថែទាំផ្សេងទៀត ដើម្បីជួយធានាឱ្យមានការផ្លាស់ប្តូរដោយរលូន ត្រឡប់ទៅកាន់ក្រុមថែទាំសុខភាពធម្មតារបស់អ្នកវិញ។

សម្រាប់ព័ត៌មានបន្ថែម៖

ចូលមើលគេហទំព័រ
**myhomehospital.sa.gov.au**

ឬទូរសព្ទមកយើងនៅតាម
**1800 111 644**

សម្រាប់អ្នកជំងឺរបស់ My Home Hospital៖

**ប្រសិនបើអ្នកមានការព្រួយបារម្ភ ឬប្រសិនបើស្ថានភាពរបស់អ្នកផ្លាស់ប្តូរ សូមទូរសព្ទទៅបណ្តាញទូរសព្ទជំនួយបន្ទាន់របស់ My Home Hospital៖**

**1800 000 644**

**ក្នុងគ្រាអាសន្នផ្នែកវេជ្ជសាស្ត្រ សូមទូរសព្ទទៅលេខសូន្យបីដង (000) ជាបន្ទាន់។**

សាធារណៈ: - I1 - A1

BY NC ND
https://creativecommons.org/licenses

©SA Health រដ្ឋាភិបាលរដ្ឋអូស្ត្រាលីខាងត្បូង។
រក្សាសិទ្ធគ្រប់យ៉ាង។
FIS: 21012.1 បោះពុម្ព៖ ខែកញ្ញា ឆ្នាំ 2021

Government of South Australia
SA Health

# My Home Hospital

Khmer | ភាសាខ្មែរ



**My Home Hospital គឺជាសេវាកម្មមន្ទីរពេទ្យសាធារណៈ ដែលនាំយកការថែទាំកម្រិតមន្ទីរពេទ្យមកជូនអ្នក ប្រកបដោយផាសុខភាព និងភាពឯកជននៅក្នុងផ្ទះផ្ទាល់ខ្លួនរបស់អ្នក។**

Government of South Australia
SA Health

# តើ My Home Hospital គឺជាអ្វី?

My Home Hospital គឺជាសេវាកម្មកម្រិតមន្ទីរពេទ្យសាធារណៈ ដែលផ្តល់ការថែទាំសុខភាពដល់មនុស្ស ប្រកបដោយផាសុខភាព និងភាពឯកជននៅក្នុងផ្ទះផ្ទាល់ខ្លួនរបស់ពួកគេ។

សេវាកម្មរបស់ My Home Hospital៖

- អាចរកបានដោយឥតគិតថ្លៃ សម្រាប់អ្នកជំងឺសាធារណៈដែលមានសិទ្ធិទទួល 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍
- សេវាកម្មនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់ឱ្យអ្នកនូវការថែទាំវេជ្ជសាស្ត្រតាមផ្ទះ សម្រាប់ស្ថានភាពសុខភាពស្រួចស្រាវ ដែលការថែទាំនៅផ្ទះត្រូវបានចាត់ទុកថាមានសុវត្ថិភាព និងសមស្រប
- នាំមកនូវការថែទាំក្នុងទម្រង់ជាវេជ្ជបណ្ឌិត គិលានុប្បដ្ឋាក អ្នកអនុវត្តសម្ព័ន្ធសុខភាព ការថតកាំរស្មីអ៊ិច និងការធ្វើតេស្តឈាមមួយចំនួន ថ្នាំពេទ្យ និងសេវាកម្មគាំទ្រផ្សេងទៀតដូចជាអាហារ និងការថែទាំផ្ទាល់ខ្លួន ប្រសិនបើចាំបាច់។
- ផ្តល់ជូនផែនការថែទាំជាលក្ខណៈផ្ទាល់ខ្លួនដែលបានបង្កើតឡើងក្នុងភាពជាដៃគូជាមួយអ្នក និងក្រុមថែទាំសុខភាពធម្មតារបស់អ្នក។

## តើខ្ញុំមានសិទ្ធិចូលប្រើប្រាស់ My Home Hospital ទេ?

ដើម្បីមានសិទ្ធិចូលប្រើប្រាស់ My Home Hospital អ្នកត្រូវ៖

- ✓ ផ្តល់ការយល់ព្រមរបស់អ្នក វាអាស្រ័យលើអ្នក ប្រសិនបើអ្នកជ្រើសរើសដើម្បីព្យាបាលនៅតាមផ្ទះ
- ✓ ត្រូវបានបញ្ជូនបន្តដោយ GP របស់អ្នក អ្នកឯកទេស អ្នកព្យាបាលគិលានុប្បដ្ឋាករបស់អ្នក ឬពីសេវាកម្មរថយន្តសង្គ្រោះបន្ទាន់រដ្ឋអូស្ត្រាលីខាងត្បូង (SAAS) មន្ទីរសង្គ្រោះបន្ទាន់ ឬមន្ទីរពេទ្យ
- ✓ ទាមទារការថែទាំកម្រិតមន្ទីរពេទ្យសម្រាប់ស្ថានភាពនានា ដែលការថែទាំរបស់មន្ទីរពេទ្យមានមូលដ្ឋានតាមផ្ទះមានសុវត្ថិភាព និងសមស្រប
- ✓ រស់នៅក្នុងតំបន់ជុំវិញក្រុងអាដឺឡែត ឬនៅតំបន់ទីជនបទងដែលបានជ្រើសរើស
- ✓ មានសិទ្ធិប្រើប្រាស់ទូរសព្ទដៃ ឬទូរសព្ទលើតុដើម្បីហៅ និងទទួលការហៅទូរសព្ទ
- ✓ មានបរិយាកាសផ្ទះដែលមានសុវត្ថិភាពសម្រាប់ខ្លួនអ្នក និងអ្នកជំនាញផ្នែកសុខភាពដែលផ្តល់សេវាកម្ម

## តើខ្ញុំអាចចូលប្រើប្រាស់ My Home Hospital ដោយរបៀបណា?

ប្រសិនបើអ្នកត្រូវបានបញ្ជូនបន្តទៅ My Home Hospital អ្នកសម្របសម្រួលក្នុងការថែទាំម្នាក់នឹងទាក់ទងអ្នក ដើម្បីពិភាក្សាអំពីលក្ខណៈវិនិច្ឆ័យសិទ្ធិទទួល រួមទាំងអ្វីៗដូចមានចុះបញ្ជីខាងលើ។

អ្នកនឹងមានឱកាសដើម្បីសួរសំណួរណាមួយដែលអ្នក មនុស្សជាទីស្រឡាញ់ ឬអ្នកថែទាំរបស់អ្នកអាចមាន។ ប្រសិនបើចាំបាច់ អ្នកសម្របសម្រួលក្នុងការថែទាំក៏នឹងទាក់ទងអ្នកបញ្ជូនបន្ត សម្រាប់ព័ត៌មានបន្ថែមផងដែរ។

ក្នុងរយៈពេល 30 នាទី បន្ទាប់ពីការទទួលបានព័ត៌មានទាំងអស់ដែលយើងត្រូវការ នោះ My Home Hospital នឹងទទួលយកអ្នកចូលមកក្នុងសេវាកម្ម ហើយប្រាប់អ្នកនៅពេលណាដែលអ្នកអាចអញ្ជើញមកពិនិត្យជាលើកដំបូង ឬក៏ទាក់ទងអ្នកបញ្ជូនបន្ត ដើម្បីពិភាក្សាអំពីការរៀបចំជំនួសនានា។

## ហេតុអ្វីបានជាខ្ញុំជ្រើសរើស My Home Hospital?

អ្នកនឹងអាចទទួលបានការថែទាំប្រកបដោយផាសុខភាព និងភាពឯកជននៅក្នុងផ្ទះផ្ទាល់ខ្លួនរបស់អ្នក ហើយចំណាយពេលច្រើនជាមួយមនុស្សជាទីស្រឡាញ់ និងសត្វចិញ្ចឹម។

អ្នកនឹងអាចគេងលើគ្រែរបស់អ្នក ហើយបរិភោគអាហារដែលអ្នកចូលចិត្ត។

My Home Hospital គឺជាមន្ទីរពេទ្យសាធារណៈនៃរដ្ឋអូស្ត្រាលីខាងត្បូង ហើយបំពេញតាមស្តង់ដារខ្ពស់ដូចគ្នាសម្រាប់ការថែទាំផ្នែកគ្លីនិក សុវត្ថិភាពអ្នកជំងឺ និងសុវត្ថិភាពនៃព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកដែរ។

មនុស្សជាទីស្រឡាញ់ និងមិត្តភ័ក្តិ អាចទៅលេងអ្នកនៅពេលណាដែលស័ក្តិសមនឹងអ្នក។

